SWIS-H
STATEWIDE INFANT SCREENING - HEARING



# ហេតុអ្វីបានជាទារករបស់ខ្ញុំត្រូវការការពិនិត្យមើលសោតវិញ្ញាណម្តងទៀត?

ទារកជាច្រើនត្រូវការការពិនិត្យមើលសោតវិញ្ញាណម្តងទៀត។

ការនេះមិនចាំបាច់មានន័យថាទារករបស់អ្នកបានបាត់បង់សោតវិញ្ញាណឡើយ។ វាអាចមានហេតុផលឯទៀតដើម្បីតម្រូវឲ្យមានការពិនិត្យមើលលើកទី២។

ហេតុផលទូទៅភាគច្រើន ដែលតម្រូវឲ្យមានការពិនិត្យមើលម្តងទៀតគឺការមានវត្ថុរាវ ឬការរាំងខ្ទប់ក្នុងត្រចៀករបស់ទារកអ្នកក្រោយពេលកើតមក។

ក្នុងករណីជាច្រើន ការពិនិត្យមើលសោតវិញ្ញាណម្តងទៀតនឹងធ្វើឡើងមុនពេលអ្នក និងទារករបស់អ្នកចាកចេញពីមន្ទីរពេទ្យ។

ប្រសិនបើគេពុំអាចផ្តល់ជូនការពិនិត្យមើលសោតវិញ្ញាណបានទេ ក្នុងពេលដែលអ្នកកំពុងនៅក្នុងមន្ទីរពេទ្យ ទារករបស់អ្នកនឹងបានទទួលការពិនិត្យមើលសោតវិញ្ញាណម្តងទៀតក្នុងភាពជាអ្នកជំងឺពុំដេកក្នុងមន្ទីរពេទ្យ ឬនៅតាមទីកន្លែងសហគមន៍ក្នុងតំបន់ក្នុងពេលឆាប់ៗក្រោយពេលចាកចេញពីមន្ទីរពេទ្យ។

បុគ្គលដែលផ្តល់កូនសៀវភៅព័ត៌មាននេះមកអ្នក នឹងប្រាប់អ្នកឲ្យបានដឹងថាតើការពិនិត្យមើលសោតវិញ្ញាណនឹងធ្វើនៅពេលណា ហើយនៅទីកន្លែងណា។

## លទ្ធផល

ក្រោយពេលការពិនិត្យមើលសោតវិញ្ញាណបានបំពេញរួចភ្លាមនោះ គេនឹងពន្យល់ប្រាប់លទ្ធផលជូនអ្នក ហើយកត់ត្រាវាទុកក្នុងកំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ទារកអ្នក (សៀវភៅខៀវ)។

ប្រសិនបើការពិនិត្យមើលសោតវិញ្ញាណម្តងទៀត ពុំបង្ហាញឲ្យឃើញលទ្ធផលច្បាស់លាស់ទេ ទារករបស់អ្នកនឹងត្រូវបានគេបញ្ជូនទៅសម្រាប់ការវាយតម្លៃរោគវិនិច្ឆ័យសោតវិញ្ញាណដោយគ្រូពេទ្យសោតវិញ្ញាណ។ គ្រូពេទ្យសោតវិញ្ញាណគឺជាអ្នកឯកទេសខាងការធ្វើតេស្តសោតវិញ្ញាណ។

ជាការសំខាន់ដែលអ្នកត្រូវស្វែងយល់ឲ្យបានដឹងយ៉ាងឆាប់ តាមលទ្ធភាពអាចធ្វើទៅបានថាតើទារករបស់អ្នកស្តាប់ឮល្អយ៉ាងណាដែរដើម្បីឲ្យអ្នក ហើយនិងទារករបស់អ្នកអាចទទួលបានឱវាទ និងការផ្គត់ផ្គង់ត្រឹមត្រូវ។

### សម្រាប់ព័ត៌មានបន្ថែម សូមបើកចូលវិបសាយខាងក្រោមនេះ៖

http://www.health.nsw.gov.au/kids-families

ការទាក់ទងក្នុងតំបន់ / ព័ត៌មានលំអិតអំពីការណាត់ជួប

សម្រាប់ឱវាទផ្នែកសុខភាព សូមទាក់ទង *healthdirect Australia*
http://www.healthdirect.gov.au/
**1800 022 222**

**Khmer** - Why does my baby need a repeat hearing screen?

NSW GOVERNMENT | Health

© NSW Health September 2016 SHPN (NKF)150194